# ការសម្ភាសរបស់បងស្រី ទេស សុគន្ធា

កៈ អ្នកសម្ភាសគេឈ្មោះជាង ស៊ីអ៊ាវ  ខៈ អ្នកទទួលការសម្ភាស ទេស សុគន្ធា

## <u>ការសង្ខេបប្រវត្តិរបស់បងស្រីទេស សុគន្ធា</u>

បងស្រី ទេស សុគន្ធា មានអាយុ៦០ឆ្នាំនៅក្នុងឆ្នាំ២០១៩ មានភេទ ប្រុស មានទីលំនៅបច្ចុប្បន្ននៅភូមិយបាត ឃុំក្បាលកោះ ខ័ណ្ឌច្បារអំពៅ រាជធានីភ្នំពេញ៕

កៈ ចឹងជាដំបូងខ្ញុំអរគុណច្រើនបងដែរបានអោយខ្ញុំពិភាក្សាជាមួយបងទាក់ទងពីប្រវត្តិរបស់បង ហើយការសម្ភាសទាំងអស់នេះត្រូវរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថា BYUពីហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅជំនាន់ក្រោយពួកគាត់បានស្គាល់ហ្នឹងបានដឹងពីប្រវត្តិឪពុកម្ដាយហ្នឹងដូនតា ចឹងសំរាប់បងយល់ព្រមដើម្បីអោយខ្ញុំដាក់ការសម្ភាសទាំងអស់ហ្នឹងទៅក្នុងវេបសាយសាលាទេបង?

ខៈ ចា៎!

កៈ ចឹងសំរាប់ខ្ញុំជាអ្នកសម្ភាសបងខ្ញុំមានឈ្មោះថាជាង ស៊ីអ៊ាវហើយថ្ងៃខែដែរខ្ញុំសម្ភាសបងគឺនៅថ្ងៃទី២៧ ខែ១ឆ្នាំ២០១៩ ហើយការសម្ភាសទាំងអស់ហ្នឹងគឺធ្វើឡើងភូមិហ្នឹងភូមិអីគេបង?

ខៈ ភូមិហ្នឹងភូមិស្នាយ។

កៈ បឹងស្នាយហេសបង?

ខៈ បឹងស្នាយ។

កៈ ឃុំបឹងស្នាយ?

ខៈ ចា៎!

កៈ ស្រុកកំពង់ចាម ខេត្តកំពង់ចាមណេះបង?

ខៈ ចា៎!

កៈ បាទ!

ខៈ ដែងទើបមកនៅទេ។

កៈ បងពីមុនបងនៅណាបង?

ខៈ ខ្ញុំនៅពីមុនខ្ញុំនៅខ្ញុំនៅភ្នំពេញនោះទេមេអោយចុះសកម្មភាព។

កៈ អ៎ូ!

ខៈ អ៎ូនៅកំពង់ចាម។

កៈ បាទបងបាទចឹងសំរាប់ឈ្មោះពេញរបស់បងម៉ងឈ្មោះអីគេបង?

ខៈ ខ្ញុំហេស?

ក៖ បាទបង!

ខ៖ ឈ្មោះខ្ញុំពិតហេស?

ក៖ បាទទាំងត្រកូលហាស?

ខ៖ ត្រកូលខ្ញុំឈ្មោះទេស សុគន្ធា។

ក៖ ទេស សុគន្ធា?

ខ៖ ចាំ!

ក៖ ទេស សុគន្ធា?

ខ៖ ចាំ!

ក៖ អូ៎ឈ្មោះពិរោះម៉េសបង?

ខ៖ ពិរោះ។

ក៖ ចុះចឹងមានឈ្មោះហៅក្រៅទេបង?

ខ៖ ឈ្មោះក្រៅមានតែឈ្មោះធា។

ក៖ ឈ្មោះធាណេះបងណេះ?

ខ៖ ចាំ!

ក៖ ចុះបងកាលពីក្មេងធ្លាប់មាននរណាគេហៅឈ្មោះបងអីផ្សេងពីហ្នឹងទៀតអត់បង?

ខ៖ អូ៎នៅពីក្មេងមិនបាច់ទេច្រើនណាស់ឈ្មោះ។

ក៖ ឈ្មោះអីគេខ្លះទៅបង?

ខ៖ ពីមុនឈ្មោះម៉ាប់ ម៉ាប់ចឹងទៅឈ្មោះផាន់ម៉ៃវាហៅចេះហៅហៅពេកហើយ!

ក៖ ចុះកាលពីមុនបងម៉ាប់មែនហោសបងហោស?
ខ៖ ខ្ញុំពីមុនម៉ាប់មែន។

ក៖ ឥឡូវនៅតែម៉ាប់ដដែលអត់ទេនិយាយលេងទេបង?

ខ៖ ទេខ្ញុំទើបមានប្តីហ្នឹងទើប....

ក៖ ស្រកទំងន់ខ្លះ?

ខ៖ ចាំ!

ក៖ ពីមុនបងធាត់ជាងហ្នឹងណេះបង?

ខ៖ អើពីមុនខ្ញុំប៉ុន្មានគីឡូកៅជាងហោស!

ក៖ អូ៎!

ខ៖ នៅខ្វះតែមួយគីឡូជិតមួយរយគីឡូនៅពីក្រមុំ។

ក៖ អូ៎ដល់ពេឥឡូវបងស្រកច្រើនហាសណេះបង?

ខ៖ ចាំ!

ក៖ ចុះបងគិតថាសព្វថ្ងៃបងអាយុប៉ុន្មានទៅឥឡូវបង?

ខ៖ តាំងពីខ្ញុំនៅក្មេងខ្ញុំអាយុអើរទើបម្ភៃជាងទៅម្ភៃបី។

ក៖ ដល់ពេលឥឡូវ?

ខ៖ ឥឡូវខ្ញុំសាមសិបប្រាំបួន។

ក៖ ឥឡូវសាមសិបប្រាំបួនឆ្នាំណេះបងណេះ?

ខ៖ ចា៎!

ក៖ អូ៎ចុះបងកើតនៅថ្ងៃខែឆ្នាំណាបងចាំទេបង?

ខ៖ អើខ្ញុំកើតខែឆ្នាំហេស?

ក៖ បាទបង!

ខ៖ ខ្ញុំកើតថ្ងៃខែដប់អើថ្ងៃទីប្រាំបួនខែដប់ឆ្នាំពីរពាន់អើឆ្នាំមួយពាន់ប្រាំបួនរយប៉ែតមួយ។

ក៖ ប៉ែតមួយណេះបង?

ខ៖ ចា៎!

ក៖ អូ៎ចុះបងគិតថាអើឆ្នាំច័ន្ទគតិជូត ឆ្លូវ ខាល ថោះបងឆ្នាំអីគេបង?

ខ៖ ខ្ញុំឆ្នាំរកា។

ក៖ ឆ្នាំរកាចុះបងកើតស្រុកកំណើតបងបងនៅណាបង?

ខ៖ ស្រុកកំណើតខ្ញុំនៅខេត្តកំពង់ស្ពឺហោស!

ក៖ នៅកំពង់ស្ពឺហោសបងហោស?

ខ៖ ចា៎!

ក៖ នៅស្រុកអីភូមិអីឃុំអីបង?

ខ៖ ខ្ញុំនៅភូមិអើក្រាំងប្រទិប ឃុំរកាធំអើ ស្រុកច្បាមន។

ក៖ ខេត្តកំពង់ស្ពឺ?

ខ៖ ក្រុងច្បារមនអូ៎ក្រុងច្បារមន។

ក៖ ខេត្តកំពង់ស្ពឺ?

ខ៖ ខេត្តកំពង់ស្ពឺ។

ក៖ អូ៎បាទបងចុះបងមានបងប្អូនបង្កើតចំនួនប៉ុន្មាននាក់បង?

ខ៖ បងប្អូនខ្ញុំបង្កើតប្រាំមួយនាក់ស្រីបី ប្រុសបី។

ក៖ បងកូនទីប៉ុន្មាន?

ខ៖ ខ្ញុំបងទីពីរ។

ក៖ អូ៎បងអាចប្រាប់ឈ្មោះបងប្អូនបងថាពួកគាត់មានឈ្មោះអីខ្លះបានទេបង?

ខ៖ អើឈ្មោះបងខ្ញុំឈ្មោះមួយទៀតអើឈ្មោះទេស សុវត្ថិ។

ក៖ ទេស សុវត្ថិហ្នឹងបងគេណេះបង?

ខ៖ ហ្នឹងបងគេខ្ញុំហោសបានបន្ទាប់ខ្ញុំ?

កៈ ទេស សុគន្ធា?

ខៈ ចាំ!

កៈ បន្ទាប់ទៀត?

ខៈ បន្ទាប់មកទៀតប្អូនអើទេស សុខំ។

កៈ ទេស សុខំ?

ខៈ ប្អូនមួយទៀតទេសអើទេសមួយទៀតទេសស្វិត។

កៈ ទេស ស្វិត?

ខៈ ចាំគេហៅស្វិតៗស្វិតមែន។

កៈ បាទ!

ខៈ ហើយប្អូននោះមួយទៀតកាលមួយទៀតទេសផល្លី មួយទៀតផល្លីផលមួយទៀតឈ្មោះផល្លីហើយមួយទៀតឈ្មោះអីគេទេពៅហោសចាំឈ្មោះវាមិនបានទេ។

កៈ អ៊ូបងអត់ចាំទេណេះ?

ខៈ ចាំមីពៅគេ។

កៈ ចុះបងគិតថាបងធ្លាប់មានអនុស្សាវរីយ៍អីជាមួយបងប្អូនបងកាលនៅក្មេងអត់បងធ្លាប់ធ្វើអីគេខ្លះដែរបងចង់ចាំហាសបង?

ខៈ អើមិនបាច់និយាយនិយាយនាំទឹកភ្នែកទេ។

កៈ ម៉េចចឹងបង?

ខៈ ជំនាន់ណុងវាជួចត់ពេកវាហត់នឿយ។

កៈ ចឹងហោសបង?

ខៈ ចាំ!

កៈ យើង..?

ខៈ យើងនៅពីក្មេងព្រោះរឿងអីនៅលើយើងទាំងអស់បងប្អូនយើងទាំងអស់។

កៈ បាទបង!

ខៈ យើងហត់នឿយលើខ្លួនយើងទាំងអស់។

កៈ អ៊ូបាទបង!

ខៈ ការងារស្រីក៏យើងចេះការងារប្រុសក៏យើងចេះ។

កៈ អើម៉េចចឹងបង?

ខៈ អើបើយើងមានឪពុកឪពុកនៅឆ្ងាយ។

កៈ ចុះរួចទៅយើងចឹង..?

ខៈ មានតែយើងហ្នឹងឯងនេះអ្នកគ្រប់គ្រង។

ក៖ បងប្អូនអី..?

ខ៖ ចេះដាងគេចាំ!

ក៖ ចុះបងគិតថាបងចូលចិត្តធ្វើអីជាមួយបងប្អូនបងទៅនៅជំនាន់ណុងហាស?

ខ៖ ជំនាន់ណុងមានអីទេបងប្អូនខ្ញុំគេធ្វើការផ្សេងៗគ្នាចឹងទៅខ្ញុំរឿងស្រែភ្លឺគេបងមានគ្រួសារបាត់ទៅនៅយើងយើងអ្នកគ្រប់គ្រង។

ក៖ បាទបង!

ខ៖ ការងារអីនៅលើយើងទាំងអស់ហត់នឿយអីរឿងរបស់យើងទាំងអស់ហោសប្អូនៗមានអីហត់ហត់តែយើងបងគេ។

ក៖ បាទបងបាទ!

ខ៖ ហត់ជាងគេត្រូវមាត់ជាងគេយើងបងគេ។

ក៖ បាទបង!

ខ៖ ហ្នឹងការងារនៅក្រមុំ។

ក៖ អូ៎បាទចុះបងគិតថាសំរាប់ដូចជាអើប្អូនហ្នឹងបងរបស់បងឥឡូវសព្វថ្ងៃគាត់នៅណាហើយគាត់ធ្វើអីសំរាប់ចិញ្ចឹមជីវិតចិញ្ចឹមក្រុមគ្រួសារបង?

ខ៖ ប្អូនខ្ញុំមួយទៀតគេលក់ដូរមួយទៀតលក់ដូរចាប់ហ្វ៊យនៅផ្ទះអើមួយទៀតគេមានប្តីមីពៅមីបងខ្ញុំបងខ្ញុំមុនគេគាត់ធ្វើការខាងនេះគាត់ធ្វើការខាងពុះអូស ពុះអីចឹងទៅណាស់បងខ្ញុំ។

ក៖ បាទបង!

ខ៖ គាត់ខាងអើដឹកអូសពីរអារើចឹងមកយកមកពុះ។

ក៖ អូ៎!

ខ៖ ហ្នឹងបងខ្ញុំ។

ក៖ បាទអ៊ុំ!

ខ៖ ហើយប្អូនខ្ញុំមីមួយទៀតអាមួយហ្នឹងវាពុះអូសវាដាក់ម៉ងដាក់អីចឹងទៅណាស់វាអត់វាបានប្រពន្ធមកក្រណាស់វាហ្នឹង!

ក៖ អូ៎បាទបងបាទ!

ខ៖ ដល់អាទីបីណុងអាទីបួនណុងគ្នានៅរៀន។

ក៖ អូ៎បាទបងចុះបងគិតថាឪពុករបស់បងឈ្មោះអីគេបង?

ខ៖ ឪពុកខ្ញុំឈ្មោះទេស សុវត្ថិ។

ក៖ ទេស សុវត្ថិឪពុកហាស?

ខ៖ ចាំ!

ក៖ ចុះឥឡូវគាត់នៅណាបង?

ខ៖ ប៉ាខ្ញុំនៅកំពង់ស្ពឺហោស!

ក៖ អូ៎ចុះម្ដាយបង?

ខ៖ ម្ដាយខ្ញុំស្លាប់បាត់ហើយ!

ក៖ តែគាត់ឈ្មោះអីគេបង?

ខ៖ គាត់ឈ្មោះអើខឹម កំសត់។

ក៖ ខឹម កំសត់?

ខ៖ ចា៎!

ក៖ ឈ្មោះពិរោះហាសណេះបង?

ខ៖ ចា៎!

ក៖ ចុះអើដូចជាឪពុកម្ដាយបងគាត់អ្នកស្រុកនៅណាបង?

ខ៖ ចា៎!

ក៖ ឪពុកម្ដាយបងគាត់អ្នកស្រុកនៅណា?

ខ៖ ស្រុកកំណើតគាត់នៅកំពង់ស្ពឺ។

ក៖ អូ៎!

ខ៖ បើប៉ាខ្ញុំគាត់នៅអើត្រាំងត្រឡាច។

ក៖ ត្រាំងត្រឡាច?

ខ៖ ចា៎!

ក៖ អូ៎ចុះឪពុករបស់បងគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិត ចិញ្ចឹមក្រុមគ្រួសារបង?

ខ៖ កាលណុងគាត់ធ្វើការទាហ៊ានតែទាហ៊ានស៊ីវិលខាងអើស៊ីវិលហ្នឹងស៊ីវិលខាងកត់អីគេទេ ស៊ីវិលហ្នឹងស៊ីវិលខាងចាប់អើចាប់ឈើចាប់អីហ្នឹង!

ក៖ បាទបងបាទ!

ខ៖ អាហ្នឹងចិញ្ចឹមជីវិតកូនចៅ។

ក៖ រួចចុះម្ដាយ?

ខ៖ ម្ដាយខ្ញុំនៅពីចិញ្ចឹមកូនហ្នឹងគាត់មានអីគាត់ដើរតែប៉ះស្លឹកថ្នឹង ស្លឹកអំពិល។

ក៖ អូ៎បាទបង!

ខ៖ ដកព្រលិតដកក្អារឈូកចិញ្ចឹមកូនហាស!

ក៖
បាទចុះសំរាប់ដូចជាអើបងធ្លាប់មានអនុស្សាវរីយ៍អីជាមួយឪពុកម្ដាយកាលបងនៅជាមួយពួកគាត់ទេបង?

ខ៖ អើកាលនៅជាមួយគាត់បើនិយាយទៅនិយាយច្រើនហាសជាមួយម៉ែឪល្វីងជូចត់ណាស់។

ក៖ អូ៎!

ខ៖ យើងហត់ណាស់យើងត្រូវប៉ុនណុងណាស់។

ក៖ ប៉ុន្តែបងអាចប្រាប់រឿងមួយចំនួនដែរថាបងមានការលំបាកអីជាមួយឪពុកម្ដាយអីទេបង?

ខ៖ ការលំបាកជាមួយឪពុកម្ដាយមានហត់ត្រង់ថាយើងខែស្រែភ្លឺមានឪពុកណា។

ក៖ មានតែម្ដាយទេណេះ?

ខ៖ មានតែខ្លួនឯងមានតែម្ដាយទេ។

ក៖ អូ៎ប៉ុន្តែពេលណុងយើងធ្វើអីគេទៅបង?

ខ៖ កាលណុងខ្ញុំព្រលឹមឡើងខ្ញុំទៅព្រលឹមឡើងជួយលើកឥវ៉ាន់ម៉ែទៅលក់ព្រលឹមឥវ៉ាន់ទៅលក់ខ្លួនឯងម៉ោងបីម៉ោងបីជាង។

ក៖ អូ៎!

ខ៖ ម៉ោងបីយើងហ្នឹងយើងទៅលក់ដូរទាល់ម៉ោងបួនជាងដល់ផ្សារលិចណុងវាឆ្ងាយ។

ក៖ ចុះអើចឹងវាពិបាកខ្លាំងហេសបង?

ខ៖ ចា៎!

ក៖ អូ៎ចុះអើបងឪពុកម្ដាយធ្លាប់ប្រាប់ពីប្រវត្តិកាលនៅក្មេងទៅបងទេ?

ខ៖ អើម៉ែខ្ញុំប្រវត្តិនៅក្មេងខ្ញុំស្ដាប់ប្រវត្តិម៉ែខ្ញុំយាយៗគាត់មកប្រវត្តិម៉ែខ្ញុំនៅពីតូចនៅពីក្មេងក៏ហត់នឿយដែរគាត់ពិបាកដែរបងប្អូនគាត់មានដប់ពីរនាក់។

ក៖ បាទ!

ខ៖ ស្លាប់ជំនាន់ប៉ុលពតហ្នឹងអស់ហើយនៅតែពីរនាក់ទេ។

ក៖ បាទ!

ខ៖ ពីរនាក់ហ្នឹងនៅតែប្រុសស្រីៗហ្នឹង!

ក៖ បាទបងបាទ!

ខ៖ ជំនាន់ហ្នឹងចូលយើងចូលជំនាន់ប៉ុលពតវិញមានស្អីទាល់យើងប្រឹងរកស៊ីបានបានមានបានហ្នឹងគេ។

ក៖ បាទបងបាទ!

ខ៖ ជំនាន់ប៉ុលពតហ្នឹងមានអីទៀតអស់ហើយហ្នឹង!

ក៖ បាទបង!

ខ៖ យើងមានអីយើងមានតែវេចស្អីប៉េ អន្ទង់ចេកអន្ទង់អីហ្នឹងលក់ដូរហ្នឹងណាស់។

ក៖ អូ៎បាទបង!

ខ៖ ជំនាន់ហ្នឹង!

ក៖ អូ៎!

ខៈ បានយាយៗខ្ញុំហ្នឹងចិញ្ចឹមចៅដើម្បីជីវិតកូនចៅហ្នឹងអោយជំនាន់ក្រោយហ្នឹងខំប្រឹងរៀនសូត្រ។

កៈ បាទចុះសំរាប់យាយតាខាងឪពុកបងស្គាល់ឈ្មោះគាត់ទេបង?

ខៈ អើខ្ញុំអត់ទាន់តាខ្ញុំផងតាខ្ញុំស្លាប់បាត់ហើយតាស្លាប់តាំងពីជំនាន់ប៉ុលពតនៅហោស!

កៈ បាទប៉ុន្តែគាត់មានធ្លាប់ប្រាប់ថាគាត់មានឈ្មោះអីគេអត់បង?

ខៈ អើអត់ដែរស្គាល់ទេយាយតាខ្ញុំហោស!

កៈ អូ៎!

ខៈ ខ្ញុំស្គាល់តែយាយ។

កៈ ប៉ុន្តែយាយឈ្មោះអីគេបង?

ខៈ យាយខ្ញុំឈ្មោះយាយយ៉ង់។

កៈ ចុះ..?

ខៈ កែវ យ៉ង់។

កៈ ហ្នឹងយាយខាងណាបង?

ខៈ យាយខាងខ្ញុំយាយខ្ញុំបង្កើត។

កៈ ប៉ុន្តែខាងណាខាងម្ដាយខាងឪពុក?

ខៈ ខាងម្ដាយ។

កៈ ចុះខាងឪពុកវិញបង?

ខៈ ខាងឪពុកខ្ញុំឈ្មោះយាយខាងយាយខ្ញុំឈ្មោះមានអីឈ្មោះមានតែទេស។

កៈ ទេសហ្នឹងឈ្មោះតាវីក៏ឈ្មោះយាយ?

ខៈ ឈ្មោះយាយ។

កៈ យាយហោស?

ខៈ បើតាខ្ញុំឈ្មោះអើឈ្មោះអើទេសតែទេស ទេសង៉ែត។

កៈ ទេសង៉ែតហោសបងណេះ?

ខៈ តាអូ៎យាយខ្ញុំឈ្មោះអើទេសហ្នឹងក៏ទេសអើស្អីអីទេភ្លេចគាត់បាត់ទៅហើយ!

កៈ អូ៎បងភ្លេចបាត់ហើយហោសបង?

ខៈ មានទេសឈ្មោះគាត់ពិតប្រាកដហៅក្រៅមានតែយាយសែ។

កៈ យាយសែ?

ខៈ ចាំយាយសែ។

កៈ អូ៎!

ខៈ ជំនាន់ខាងឪពុកខ្ញុំ។

កៈ បាទបង!

ខៈ ម៉ែឪពុកខ្ញុំហាសណាស់។

កៈ បាទ!

ខៈ
តែម្ដាយឪពុកម៉ែខ្ញុំឪខ្ញុំហ្នឹងស្លាប់បាត់ហើយឪពុកគាត់ប្រវត្តិស្លាប់ទាន់ជំនាន់ប៉ុលពតអស់ហើយនៅតែអើម៉ែទេ។

កៈ បាទបងចុះអើសំរាប់ដូចជាបងមករស់នៅហ្នឹងយូរនៅបង?

ខៈ ខ្ញុំទើបមកនៅមិនទាន់បានមួយខែផង។

កៈ អើ!

ខៈ
ខ្ញុំទើបមកនៅទេមកទើបមើលចុះសកម្មភាពនៅខេត្តកំពង់ចាមហ្នឹងមុនដំបូងខ្ញុំនៅផ្ទះជួលហ្នឹងហើយ!

កៈ អើពីមុនបងនៅណាទៅចឹង?

ខៈ ពីមុននៅការាស់ស៊ីនទ្រីហោស!

កៈ អូ៎គេទើបអោយបងនៅហ្នឹងហោស?

ខៈ
ចុះមកហ្នឹងការ៉ាស់ស៊ីនទ្រីយើងថាអើពិបាកអាចម៍ច្អេសច្អាចម៍ណាស់លោកអើអាពេជ្រអាពាថ់និយាយទៅនៅណុងវាស្មោគគ្រោកពេក។

កៈ ចឹងហោសបង?

ខៈ ហើយកូនងាកឈឺពេកនោះអាមួយនោះងាកឈឺៗហោស!

កៈ បាទបង!

ខៈ សុខចិត្តនៅហ្នឹងទៅ។

កៈ អូ៎ការ៉ាស់ហ្នឹងពីមុននៅណាបង?

ខៈ ការ៉ាស់យើងការ៉ាស់ស៊ីនទ្រីយើងនៅអើមុននៅនេះហោសជំនាន់ណុង..។

កៈ បុសខ្ទុរ?

ខៈ ចាំខ្ញុំទើបមកនៅបាននិយាយទៅបាននៅស៊ីនទ្រីបានពីរឆ្នាំ។

កៈ អូ៎!

ខៈ ទើបខ្ញុំបានមកនៅនេះ។

កៈ បាទបងបាទចុះ..?

ខៈ មកទិញគេនៅនេះដីផ្ទះហ្នឹង!

កៈ បាទបងចុះបងគិតថាស្វាមីរបស់បងឈ្មោះអីគេបង?

ខៈ ឈ្មោះអើស្វាមីខ្ញុំឈ្មោះអើជូ មករា។

កៈ ជូ មករា?

ខៈ ចាំ!

កៈ ចុះគាត់ឥឡូវគាត់ធ្វើការងារអីគេបង?

ខៈ គាត់បើកឡានគ្រឿងកំប៉ុង។

កៈ អូ៎អោយក្រុមហ៊ុនគេហាសណេះបង?

ខៈ ចាំ!

កៈ បាទបងចុះបងគិតថាបងឥឡូវសព្វថ្ងៃបងមានកូនប៉ុន្មាននាក់បង?

ខៈ កូនខ្ញុំទាំងអស់បួននាក់។

កៈ បួននាក់ចុះកូនបងអាយុប៉ុន្មានទៅបង?

ខៈ មួយទៀតដប់មួយឆ្នាំមួយទៀតដប់បួន។

កៈ កូនបងដប់បួនឆ្នាំ?

ខៈ ចាំ!

កៈ ប៉ុន្តែគាត់នៅរៀនទេណេះបង?

ខៈ នៅរៀនទាំងអស់។

កៈ
អូ៎ចុះបងគិតថាអើនៅពេលដែរបងរៀបអាពាហ៍ពិពាហ៍ជាមួយស្វាមីបងគិតថាបងជាអ្នករៀបចំដោយខ្លួនឯងរឺមួយក៏ឪពុកម្តាយបងជាអ្នករៀបចំអោយពេលណុងបង?

ខៈ កាលណុងឪពុកម្តាយអ្នករៀបចំអោយ។

កៈ ចឹងហោសបងមានជំនូនអត់បងមានថ្លៃទឹកដោះអត់?

ខៈ ថ្លៃទឹកដោះអត់យកអីថ្លៃទេមួយពាន់ប្រាំរយ។

កៈ អូ៎មួយពាន់ប្រាំរយច្រើនហាសបងអូ៎ចុះបងពីមុនបងធ្លាប់បានរៀនអត់បង?

ខៈ ខ្ញុំរៀនបានត្រឹមថ្នាក់ទីបួនថ្នាក់ទីប្រាំហ្នឹង!

កៈ អូ៎!

ខៈ ជំនានណុងពិបានវេទនាណាស់ម៉ែឪគាត់អត់ពេក។

កៈ បាទ!

ខៈ ពេលណុងសុំគាត់ជួយជំនួសដៃជើងគាត់ទៅ។

កៈ បាទ!

ខៈ ឃើញគាត់ហត់ពេកម្តាយ។

កៈ
បាទចុះអើបងគិតថាដូចជាបងធ្លាប់មានមិត្តភក្តិស្និទ្ធិស្នាលដែរធំធាត់មកជាមួយគ្នាអត់បងកាលបងនៅរៀនហាស?

ខៈ អើពួកម៉ាកខ្ញុំនិយាយទៅរៀនជាមួយគ្នាសិទ្ធិស្នាលសុទ្ធតែលំដាប់អ្នកមាន។

កៈ អើ!

ខៈ គេឃើញយើងអត់គេជួយយើងណាស់យើងអត់ស៊ីចឹងគេជួយយើង។

កៈ ចឹងហោសបង?

ខៈ
ចាំព្រោះពួកម៉ាកខ្ញុំគេសុទ្ធតែពួកម៉ាកអ្នកមានរៀនជាមួយគ្នាចឹងឃើញឯងអត់ចឹងគេសុំលុយម៉ែបងប្អូនគេចឹងជួយឯងទៅទិញអង្ករទិញម្ហូបចឹងស៊ីចឹងទៅ។

កៈ អូ៎បាទ!

ខៈ អាហ្នឹងពួកម៉ាកខ្ញុំ។

កៈ អូ៎ចុះបងគិតថាបងធ្លាប់ធ្វើស្រែចំការពីមុនទេបង?

ខៈ ខ្ញុំធ្លាប់ធ្វើស្រែ។

កៈ អូ៎ធ្វើពេលណុងពេលណាបង?

ខៈ
ពេលជំនាន់ណុងជំនាន់យើងចូលចូលឆ្នាំចូលអេសនេះហើយហ្នឹងពូអើយចូលសង្រ្គាមហើយយើងនៅគ្រាប់នៅអីទៀតយើងទំរាំរើសគ្រាប់រើសអីហើយយើងធ្វើស្រែធ្វើ។

កៈ អូ៎ពេលយើងនៅតូចៗណេះបងណេះ?

ខៈ ចាំខ្ញុំនៅតូចៗខ្ញុំមិនដឹងខ្យល់អីទេ។

កៈ ប៉ុន្តែពេលហ្នឹងយើងនៅធ្វើស្រែណេះបង?

ខៈ ចាំ!

កៈ
អូ៎បាទបងចុះបងគិតថាការងារអីគេខ្លះដែរបងធ្លាប់ធ្វើតាំងពីក្មេងរហូតមកដល់ឥឡូវហាសបង?

ខៈ
កាលខ្ញុំការងារនៅពីក្មេងអើកាលខ្ញុំនៅពីក្មេងការងារអីទេនៅពីក្មេងម៉ែអោយធ្វើអីទេនៅតែផ្ទះ អោយនៅតែផ្ទះអោយនៅបោកខោអាវបោកខោអាវដាំបាយធ្វើម្ហូបស៊ីតែប៉ុណ្ណឹង។

កៈ បាទ!

ខៈ ហើយលាងចានលាងឆ្នាំងទុកដាក់ផ្ទះសំបែង។

កៈ បាទ!

ខៈ ហើយធ្វើស្មៅផ្ទះដាំផ្កាផ្ទះនៅតែប៉ុណ្ណឹងទេ។

កៈ បាទ!

ខៈ ប្តីនៅទំនេរចឹងទៅខ្ញុំរកស៊ីចាប់ហ៊ួយនៅមុខផ្ទះអាខ្លួននៅពីក្មេង។

កៈ បាទបង!

ខៈ អាហ្នឹងយើងរករបស់ខ្លួនយើងម៉ែឪរកផ្សេងកូនរកផ្សេង។

កៈ អូ៎!

ខៈ អាហ្នឹងនៅពីក្មេងខ្ញុំរៀនបណ្តើរលក់ដូរបណ្តើរ។

កៈ អូ៎!

ខ៖
ដូចថ្ងៃសៅរ៍ថ្ងៃអាទិត្យអត់រៀនចឹងទៅលក់ដូរចឹងទៅម៉ែនៅផ្ទះចឹងទៅគាត់ជួយជំនួសដៃជំនួសជើងលក់ចាប់ហ្អួយចឹងទៅ។

ក៖ បាទបងបាទ!

ខ៖ ជួយព្រលឹមឡើងចឹងទៅដើបតាំងពីម៉ោងបីទៅទិញឥវ៉ាន់យកមកអោយម៉ែលក់ដូរ។

ក៖ បាទបងចុះបង..?

ខ៖
ទាល់ម៉ោងយើងដល់យើងរៀបចំមកពីនោះមកដល់ម៉ោងបីបួនមកដល់នេះយើងរៀបចំឥវ៉ាន់លក់ដូរហើយទាល់ម៉ោងប្រាំមួយដល់ម៉ោងវាទៅរៀន។

ក៖ អូ៎បាទបង!

ខ៖ អាហ្នឹងនៅពីក្រមុំ។

ក៖ អូ៎ចុះបងគិតថាអើបងកាលពីមុនបងធ្លាប់ចិញ្ចឹមសត្វវីមួយក៏លក់ដូរអីអត់បង?

ខ៖ ខ្ញុំអត់ដែរចិញ្ចឹមទេរឿងសត្វ។

ក៖ តែបងធ្លាប់លក់ដូរ?

ខ៖ ខ្ញុំលក់តែដូរទេ។

ក៖ កាលណុងបងលក់អីគេបងកាលណុង?

ខ៖ កាលណុងខ្ញុំលក់មានអីមានតែបន្លែ សាច់ជ្រូក ត្រី។

ក៖ អូ៎បងលក់នៅផ្សារបងហោស?

ខ៖ ចា៎!

ក៖ អូ៎ចុះ..?

ខ៖ ពេលខ្ញុំនៅផ្ទះខ្ញុំមានលក់អីខ្ញុំមានលក់តែមុខរបរខ្ញុំមានអីមានតែអើគ្រឿងម្ហូរហ្នឹងម្ហូរទឹកកកក់ឈូសទំពៅ។

ក៖ អូ៎បាទបង!

ខ៖ ប៉ុណ្ណឹងខ្ញុំនៅផ្ទះ។

ក៖ បាទបងចុះបងគិតថាសំរាប់ដូចជាជីវិតរបស់បង
បងគិតថាតាំងពីក្មេងរហូតមកដល់ឥឡូវមានផ្លាស់ប្តូរអីខ្លះទៅបង?

ខ៖ ខ្ញុំផ្លាស់ប្តូរតើមានប្តី ប្តីមិនដែរអោយធ្វើអីទេអោយនៅមើលតែកូន។

ក៖ អើស្រួលហាសណេះបងណេះ?

ខ៖ ហើយចានឆ្នាំងផ្ទះសំបែងតែប៉ុណ្ណឹង។

ក៖ អូ៎តែសុខភាពអីអត់អីទេណេះបងណេះ?

ខ៖ ចា៎អត់អីទេពូ។

ក៖ អូ៎ចុះ..?

ខ៖ បើខែត្រជាក់ចឹងប្រែប្រួលកូនបានឈឺ។

ក៖ ឈឺណេះបងណេះចុះម្ហូបអីដែរបងចូលចិត្តហូបបង?

ខ៖ ខ្ញុំហេសខ្ញុំចូលចិត្តជាងគេស្លមានតែស្លម្ជូរយួន ហ្នឹងកកូរ។

ក៖ អូ៎បាទបង!

ខ៖ តែបើកូនៗគេចូលចិត្តក្រៀមក្រសណាស់។

ក៖
បាទបងបាទចុះបងគិតថាអើកាលពីក្មេងបងធ្លាប់លេងល្បែងប្រជាប្រិយ៍អីទេបងដូចលក្ខ
ណះបោះអង្គុញ ចោលឈូង លាក់កន្សែង?

ខ៖ អើបើខ្ញុំនៅពីក្មេងនៅក្រមុំចេះលេងមួយចប់។

ក៖ បងស្អីក៏លេងដែរណេះបងណេះ?

ខ៖ ស្អីក៏លេងដែរលេងលាក់កូនខ្លែងក៏ចេះលេង
លេងបីដកមួយក៏ចេះអាហ្នឹងជំនាន់ហ្នឹងអត់ដឹងអីទេក្មេងៗហោស!

ក៖ បាទបងបាទចុះបងគិតថាបងចូលចិត្តច្រៀងទេបង?

ខ៖ ខ្ញុំអត់ទេ។

ក៖ តែបងចូលចិត្តរាំ?

ខ៖
ចូលចិត្តអារឿងរាំហ្នឹងរាចេះមែនពេលរវល់ក្នុងភូមិក្នុងអីចឹងបងប្អូនគេរកចឹងទៅចេះតែទៅ
ទៅ។

ក៖ តែឥឡូវក៏នៅតែចូលចិត្តដែរ?

ខ៖ អត់ទេឥឡូវ។

ក៖ ចាស់ហើយណេះបង?

ខ៖ តាំងពីមានប្ដីមក។

ក៖ អូ៎ចុះបងគិតថាអើបងចូលចិត្តមើលល្ខោនយីកេអាយៃអីទេបង?

ខ៖ បើខ្ញុំនៅផ្ទះខ្ញុំមើលតែចូលចិត្តមើលជាគេយីកេរឿងល្ខោនមើល។

ក៖ អូ៎បាទបងចុះ..?

ខ៖ ហើយនៅផ្ទះ។

ក៖
ចុះបងគិតថាអើមាននរណាគេមួយនៅក្នុងក្រុមគ្រួសារបងចេះលេងឧបករណ៍ភ្លេងទេបង?

ខ៖ អត់មានទេឧបករណ៍ហោស?

ក៖ ខាងប្ដីបងក៏អត់មានដែរ?

ខ៖ អត់មានទេ។

ក៖
អូ៎ចុះបងគិតថាផ្ទះរបស់បងកាលបងនៅជាមួយឪពុកម្ដាយផ្ទះម៉េចបងឥឡូវបងនៅមានគ្រួ
សារផ្ទះម៉េចទៅ?

ខ៖ ផ្ទះខ្ញុំនៅស្រុកផ្ទះឈើផ្ទះពីរខ្នង។

ក៖ ដល់ពេល..?

ខ៖ ផ្ទះខ្ញុំផ្ទះបុរាណ។

ក៖ ដល់ពេលឥឡូវផ្ទះម៉េចទៅបង?

ខ៖ ផ្ទះខ្ញុំឥឡូវផ្ទះតូចផ្ទះគៀម។

ក៖ ចឹងហេសបងផ្ទះហ្នឹងយើងជាអ្នកសាងសងដោយខ្លួនឯងមែនបង?

ខ៖ អានេះគេធ្វើខ្លួនឯងទិញគេហ្នឹង!

ក៖ ទិញគេម៉ងហោសបង?

ខ៖ ចំា!

ក៖ ទិញហ្នឹងប៉ុន្មានបង?

ខ៖ ទិញហ្នឹងប៉ែតសិប។

ក៖ ប៉ែតសិបដុល្លាហោសបង?

ខ៖ ប៉ែតសិប។

ក៖ ប៉ែតសិបម៉ឺន?

ខ៖ ពីររយ។

ក៖ អូ៎ទាំងដីហ្នឹង?

ខ៖ អត់ទេដីហ្នឹងដីរបស់ភូមិរបស់...។

ក៖ ចឹងមានន័យថាយើងទិញតែផ្ទះទេ?

ខ៖ ផ្ទះទេដីដីរបស់គេ។

ក៖ អូ៎បាទ!

ខ៖ របស់ចិន។

ក៖ ចុះ..?

ខ៖ គេនៅស្នាក់នៅទេ។

ក៖ យើងនៅបណ្ដោះអាសន្ននេះបង?

ខ៖ ចំា!

ក៖ អូ៎ចុះបងគិតថាអើដូចជាជំនាញអីដែរបងចេះស្ទាត់ជំនាញបង?

ខ៖ ជំនាញដែរខ្ញុំចេះស្ទាត់ហាសកាលនៅក្រមុំខ្ញុំចង់ចេះអីចេះគ្រឿងសំអាងហ្នឹងម៉ង។

ក៖ អូ៎បាទបងប៉ុន្តែដល់ពេលឥឡូវ?

ខ៖ ឥឡូវប៉ាវមិនអោយធ្វើអីផងនៅតែផ្ទះមើលតែកូន។

ក៖ អូ៎គាត់រកបានដែរណេះបងណេះ?

ខ៖ អើរកបានតែម៉ាល្មមៗទុកចាយ។

ក៖ អូ៎!

ខៈ ម៉ាទប់ទល់គ្រូអើយរកតែម្នាក់រកអីសល់។

កៈ អ៎ូបាទបងចុះបងគិតថាអើដូចជាឪពុកម្តាយបងធ្លាប់បង្រៀនពីជំនាញអីទៅបងទេ?

ខៈ
ឪពុកម្តាយខ្ញុំនៅពីក្រមុំគាត់បង្រៀននេះគាត់បង្រៀនត្រឹមម៉ាចំនេះវិជ្ជាផ្ទាល់ខ្លួនហើយហ្នឹងរឿងអើការងារផ្ទះសំបែង។

កៈ ចឹងណេះបងណេះ?

ខៈ
ចំាហើយដល់គាត់អោយយើងដេរប៉ាក់អីចឹងអាហ្នឹងតាំងពីជំនាន់ហ្នឹងគាត់អោយទៅរៀនមែនជំនាន់ខ្ញុំនៅពីក្រមុំ។

កៈ បាទចុះបងគិតថាអើបើចង់និយាយពីផលលំបាករបស់បងវិញហាស
ការលំបាកកាលពីក្មេងហាសបងមានការលំបាកអីគេខ្លះកាលពីក្មេង?

ខៈ
ការលំបាកពីក្មេងអត់សូវលំបាកទេលំបាកពេលធំយើងធំអាយុម្ភៃជាងហ្នឹងយើងធំពិបាកអាដែង..។

កៈ យើងពិបាកអីគេខ្លះទៅបង?

ខៈ
អើម៉ែឪគាត់ពិបាកត្រង់ថាការងារអីលើគាត់ការងារស្រីក៏នៅលើគាត់ការងារប្រុសក៏នៅលើគាត់មួយចប់។

កៈ អ៎ូ!

ខៈ
ចឹងទៅយើងឃើញគាត់ពិបាកវេទនាគាត់ព្រលឹមឡើងគាត់រកស៊ីគាត់មកដល់លក់ដូរហើយគាត់ទៅស្រែ។

កៈ បាទ!

ខៈ គាត់មកពីស្រែវិញគាត់ទៅប៉ះបោចរបស់គាត់លក់ដូរទៀត។

កៈ បាទៗ!

ខៈ គាត់អត់មានទំនេរទេម្តាយខ្ញុំហោស!

កៈ
អ៎ូបាទបងចុះបងគិតថានៅពេលដែរពីមុនបងមានក្រុមគ្រួសារបងលំបាកអីខ្លះទៅបង?

ខៈ ខ្ញុំពីមុនមានគ្រួសារកាលណុងម៉ែឪខ្ញុំមានតែម្តាយអត់ឪ
ឪគាត់ទាល់មួយឆ្នាំជាងបានគាត់ទៅផ្ទះមកដល់។

កៈ បាទបងបាទ!

ខៈ
ម្តាយហើយឪពុកគាត់ហ្នឹងគាត់ដើរឆ្ងាយទៅហើយយើងនៅផ្ទះមានដីស្រែភ្លឺនៅលើយើងស្រីប្រុស។

កៈ បាទបងបាទ!

ខៈ មួយចប់គោ ពពែគោស៊ីអីនៅលើយើងទាំងអស់។

ក៖ បាទ!

ខ៖ ម៉ីគាត់ឈឺ។

ក៖ អូ៎នៅពេលដែរយើងមានគ្រួសារហើយគិតថាយើងមានការលំបាកអីទៅបង?

ខ៖ ហើយខ្ញុំមានគ្រួសារទៅខ្ញុំលំបាកមិនសូវពិបាកអីទេគាត់អោយនៅតែផ្ទះ។

ក៖ ស្រួលហាសណេះបង?

ខ៖ ដាំតែបាយបោកតែខោអាវមើលតែកូនហ្នឹង!

ក៖ អូ៎បាទបងបាទប៉ុន្តែបងចាំថាបងអត់ទាន់ជំនាន់ប៉ុលពតទេមែនទេបងណេះ?

ខ៖ ខ្ញុំអត់ទាន់ទេខ្ញុំចូលមកដាច់។

ក៖ ដាច់ហើយណេះបង?

ខ៖ ដាច់ហើយ!

ក៖ អូ៎បាទបងបាទចុះបងគិតថាអើពេលណាដែរបងគិតថាចាប់ផ្ដើមសប្បាយហាសបង?

ខ៖
អើខ្ញុំជំនាន់មិនទាន់បានសប្បាយទេចូលជំនាន់ប៉ុលពតហ្នឹងលែងមានសង្រ្គាមម្ដងទៀតគ្រាប់នៅជុំវិញផ្ទះអត់មានសប្បាយបានទេ។

ក៖ ចឹងហោសបងហោស?

ខ៖
ចាំសប្បាយទាល់តែជំនាន់យើងអើនេះហើយហ្នឹងជំនាន់ហ្នឹងជំនាន់សង្រ្គាមយើងចប់ហោសព្រោះយើងនៅរើសគ្រាប់នៅរើសអីទៀតជំនាន់ហ្នឹង!

ក៖ អាហ្នឹងបាន..?

ខ៖ សុទ្ធតែគ្រាប់សុទ្ធតែអី។

ក៖
អូ៎ប៉ុន្តែប្រហែលជាប៉ែតប៉ុន្មានកៅប៉ុន្មានដែរយើងចាប់ផ្ដើមបងគិតថាបងលែងលំបាកហាសបង?

ខ៖ ជំនាន់ណុង..។

ក៖ ពីមុន..?

ខ៖ ខ្ញុំ។

ក៖ ឬមួយក៏បងមានប្ដីបានបងគិតថាបងលែងលំបាកហើយបងសប្បាយបង?

ខ៖ អើខ្ញុំតាំងពីក្រមុំមកខ្ញុំលំបាករហូតទាល់ខ្ញុំមានប្ដីហ្នឹងមកបានគេមិនអោយធ្វើអីទេ។

ក៖ អូ៎បាទបង!

ខ៖ គេមិនអោយធ្វើអីគេអោយនៅតែមើលកូនហ្នឹង!

ក៖
បាទបងបាទចុះបងគិតថាកាលពីចាប់ពីក្មេងហាសកាលបងនៅរៀនហាសបងធ្លាប់មានគោលបំណងថាធំឡើងបងចង់ធ្វើអីមួយអត់បង?

ខ៖ នៅពីក្មេងបំណងអីអត់ចង់ធ្វើអីទេចង់តែរៀនតែគ្រឿងសំអាងហ្នឹង!

កៈ ចឹងបងហោស?

ខៈ ចា៎!

កៈ អូ៎បាទបងបាទ!

ខៈ
ខ្ញុំរៀនបានទៅអើមណ្ឌលសម្តេចឪខ្ញុំរៀនបាននៅប្រាំឆ្នាំដែររៀនបានប្រាំឆ្នាំហ្នឹងនៅហ្នឹងគេរៀននៅមណ្ឌលសម្តេចឪហ្នឹងគេអោយយើងរៀនខាងគ្រឿងសំអាងហ្នឹងមួយដែរនេះមួយ។

កៈ បាទបង!

ខៈ
រៀនយើងរៀនចប់ទៅគេអោយចូលរៀនខាងនេះទៀតត្បាញពេលចូលរៀនត្បាញរៀននេះទៀតហ្នឹងរៀនមួយចប់ប៉ុណ្ណឹងទេ។

កៈ អូ៎ចុះ..?

ខៈ
យើងរៀនចប់ចឹងទៅមេអោយធ្វើចង់អោយយើងកាន់ធ្វើមេគេធ្វើអីហ្នឹងហាសអត់ទៅរួចទេ
។

កៈ ចឹងហោសបងហោស?

ខៈ ចា៎!

កៈ
ចុះបើសិនជាចង់អោយបងផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗវិញហាសបងតើបងចង់ផ្តែផ្តាំអីទៅពួកគាត់ខ្លះបងដើម្បីអោយពួកគាត់អាចខំប្រឹងរៀនអោយគាត់មានអនាគត់ល្អអីចឹងហាសបង?

ខៈ
ខ្ញុំលោកគ្រូអើយធ្វើម៉េចអោយប្រឹងរៀនរកអនាគត់ទៅមុខហើយម៉ែឪកុំអោយវេទនាដោយសារយើងទៅបានហើយ!

កៈ បាទបង!

ខៈ
ជំនាន់ក្រោយកុំអោយម៉ែឪពិបាកចិត្តហ្នឹងរបស់ដែរគ្រឿងញៀនគ្រឿងអីហ្នឹងកុំយើងរករបស់អីដែរផ្សេងពីហ្នឹងជៀសអាគ្រឿងញៀនហ្នឹងទៅ។

កៈ អូ៎បាទបង!

ខៈ កុំអោយម៉ែឪពិបាកដោយសារយើង។

កៈ អូ៎បាទបងបាទចឹងបងមានអីផ្សេងដែរបងចង់ផ្តែផ្តាំទៀតទេបង?

ខៈ
ផ្សេងពីហ្នឹងខ្ញុំមានអីមានតែសំណូមពរក្មេងៗជំនាន់ក្រោយហោសប្រឹងរៀនអោយអនាគត់ទៅមុខកុំអោយពិបាកវេទនាដូចក្មេងៗស្ពរខ្ញុំទៅបានហើយ!

កៈ បាទបងបាទចឹងអត់មានអីទៀតទេណេះបងណេះ?

ខៈ ចា៎!

ក៖
ចឹងចុងក្រោយខ្ញុំអរគុណច្រើនបងដែរបានអោយខ្ញុំពិភាក្សាជាមួយបងទាក់ទងពីប្រវត្តិរបស់បងហើយការសម្ភាសទាំងអស់នេះ
ខ្ញុំហ្នឹងដាក់ទៅក្នុងវេបសាយសាលាដើម្បីតំកល់ទុកអោយកូនចៅជំនាន់ក្រោយរបស់បងបានស្គាល់បានដឹងចឹងហាសបង?

ខ៖ ចា៎!

ក៖ បាទអរគុណច្រើនបង។